**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៦៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០២/០០១ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីក្រមការការបរទេស
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៨ ស្តីពីការបង្កើតក្រុមវិភាគព័ត៌មាននៃខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ស្តីពីការកែសម្រួលមាត្រា៣១ មាត្រា៣២ និងមាត្រា ៣៤ និងបំពេញបន្ថែមមាត្រា ៣៤ ថ្មីស្ទួន និងមាត្រា៣៩ ស្ទួន នៃអនុក្រឹត្យ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

បង្កើតក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍ មានឈ្មោះជាអក្សរកាត់ "កសវព." ដែលស្ថិតនៅក្រោមចំណុះរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា២.-**

ក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍ ជាធនាគារខួរក្បាល(think tank) ដែលបំពេញការងារជាសេនាធិការជូនសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី និងជូនរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរ-ជាតិ លើការងារស្រាវជ្រាវ វាយតម្លៃ និទស្សន៍ វិភាគ និងព្យាករណ៍ អំពីការវិវត្តនៃស្ថានការណ៍ជាតិ និងអន្តរជាតិ។

## ជំពូកទី២
## បេសកកម្ម រចនាសម្ព័ន្ធ និងធនធានហិរញ្ញវត្ថុ

**មាត្រា៣.-**

ក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- តាមដាន និងជ្រើសរើសព័ត៌មានសំខាន់ៗទាក់ទងនឹងបច្ចុប្បន្នភាពនៃព្រឹត្តិការណ៍នៅក្នុងប្រទេស តំបន់ និងពិភពលោក ដែលមានឥទ្ធិពលដល់ការពិចារណាក្នុងការធ្វើសេចក្តីសម្រេចខាងនយោបាយក្នុង និងក្រៅប្រទេសរបស់រាជរដ្ឋាភិបាល។
- ផ្តល់នូវទស្សនទាននៃការវាយតម្លៃ វិភាគ និទស្សន៍ និងព្យាករណ៍អំពីការវិវត្តនៃស្ថានការណ៍ និងនិន្នាការនយោបាយតំបន់ និងពិភពលោក ស្ថានការណ៍នយោបាយជាតិ ស្ថានភាពសេដ្ឋកិច្ច សង្គម-វប្បធម៌ និងបញ្ហាប្រឈមទាំងឡាយ ដើម្បីបម្រើឲ្យគោលដៅនៃការសម្រេចខាងនយោបាយជាតិ និងការបរទេសរបស់កម្ពុជា។
- ស្រាវជ្រាវ និងពន្យល់អត្ថន័យប្រវត្តិសាស្ត្រ ឫសគល់នៃបញ្ហាភូមិសាស្ត្រ/យុទ្ធសាស្ត្រនយោបាយ និងព្រឹត្តិការណ៍លេចធ្លោនានានៅក្នុងប្រទេស តំបន់ និងពិភពលោក។
- តាមដានការសរសេរ ការយល់ដឹង ការវាយតម្លៃអំពីកម្ពុជានៅលើសារព័ត៌មានជាតិ អន្តរជាតិ និងក្នុងមជ្ឈដ្ឋានការទូតនានា ដើម្បីរួមចំណែកដល់ការឆ្លើយតប និងបំភ្លឺជូនសាធារណៈមតិជាតិ និងអន្តរជាតិ សំដៅការពារនូវផលប្រយោជន៍ និងកិត្យានុភាពរបស់កម្ពុជានៅលើឆាកអន្តរជាតិ។
- ផលិតព័ត៌មានប្រចាំថ្ងៃ ព័ត៌មានបច្ចុប្បន្នភាព អត្ថបទវិភាគ ឯកសារស្រាវជ្រាវយុទ្ធសាស្ត្រ និងរៀបចំជំនួយស្មារតី ជូនសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

- សម្របសម្រួលការងារជាមួយគ្រប់អង្គភាពរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងគ្រប់ក្រសួង/ស្ថាប័នរដ្ឋ ស្ថាប័នឯកជន ធនាគារខួរក្បាល គ្រឹះស្ថានឧត្តមសិក្សា វិទ្យាស្ថានស្រាវជ្រាវ រួមទាំងស្ថាប័នបរទេសផងដែរ ក្នុងបុព្វហេតុស្រាវជ្រាវ និទស្សន៍ វិភាគ និងព្យាករណ៍ឲ្យមានប្រសិទ្ធភាព។
- បំពេញការងារផ្សេងៗទៀត តាមអនុសាសន៍ និងការណែនាំរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា៤.-**

ក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍ ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួន ដែលមាននាយកដ្ឋានចំណុះចំនួន ៤ (បួន)។ ក្រុមនេះ អាចមានទីប្រឹក្សា និងជំនួយការ ព្រមទាំងអ្នកស្រាវជ្រាវ ដែលមាន ៣ (បី) កម្រិត គឺ អ្នកស្រាវជ្រាវជាន់ខ្ពស់ អ្នកស្រាវជ្រាវ និងអ្នកស្រាវជ្រាវហ្វឹកហាត់ សម្រាប់ជួយដល់ដំណើរការការងារទៅតាមការចាំបាច់។

**មាត្រា៥.-**

ក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍ មាននាយកដ្ឋានក្រោមឱវាទចំនួន ៤ (បួន) ដូចខាងក្រោម៖

- **នាយកដ្ឋានវិភាគ និងព្យាករណ៍នយោបាយតំបន់ និងពិភពលោក៖** បំពេញមុខងារស្រាវជ្រាវ តាមដាន ស្វែងយល់ ចងក្រង និទស្សន៍ វិភាគ វាយតម្លៃ និងព្យាករណ៍អំពីការវិវត្តនៃស្ថានការណ៍ និងនិន្នាការនយោបាយនៅក្នុងតំបន់ និងពិភពលោក។
- **នាយកដ្ឋានវិភាគ និងព្យាករណ៍នយោបាយជាតិ៖** បំពេញមុខងារស្រាវជ្រាវ តាមដាន ស្វែងយល់ ចងក្រង និទស្សន៍ វិភាគ វាយតម្លៃ និងព្យាករណ៍អំពីការវិវត្តនៃនយោបាយជាតិ សេដ្ឋកិច្ច សង្គម-វប្បធម៌ និងសាសនា។
- **នាយកដ្ឋានវិភាគ និងព្យាករណ៍សេដ្ឋកិច្ច និងបញ្ហាសកល៖** បំពេញមុខងារស្រាវជ្រាវ តាមដាន ស្វែង-យល់ ចងក្រង និទស្សន៍ វិភាគ វាយតម្លៃ និងព្យាករណ៍អំពីការប្រែប្រួលនៃសេដ្ឋកិច្ចនៅក្នុងតំបន់ និងពិភពលោក និងអំពីបញ្ហាប្រឈមសកលនានា។
- **នាយកដ្ឋានទ្រទ្រង់៖** បំពេញមុខងារជានាដល់ដំណើរការទ្រទ្រង់លើកិច្ចការរដ្ឋបាលទូទៅ ហិរញ្ញវត្ថុ គណនេយ្យ បច្ចេកវិទ្យាព័ត៌មាន និងផ្គត់ផ្គង់ ទុកដាក់និងរៀបចំឯកសារ/ទិន្នន័យនានា ហើយនិងសម្របសម្រួលកិច្ចការសាធារណៈជាមួយបណ្តានាយកដ្ឋាននៃក្រសួងការបរទេស និងសហប្រតិបត្តិ-ការអន្តរជាតិ និងជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីបម្រើឲ្យកិច្ចការស្រាវជ្រាវ វិភាគ និងព្យាករណ៍។

**មាត្រា៦.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានចំណុះរបស់ក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា៧.-**

ក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍ មានកញ្ចប់ថវិកា សម្រាប់ដំណើរការការងារក្នុងថវិការបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

## ជំពូកទី៣
## អន្តរប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១០ កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**ប្រាក់ សុខុន**

**កន្លែងទទួល ៖**

-ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ